# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC | Meet the Business Owner Who Received a Loan Guaranteed by CGCC

**លោកស្រី ប៉ែន បុប្ផា នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលឫទ្ធិពល**






KH ដោយមើលឃើញថាការយល់ដឹងអំពីហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជាយើងនៅមានកម្រិត ហើយការប្រើប្រាស់និងការចាត់ចែងហិរញ្ញវត្ថុរបស់ពួកគាត់មិនសូវមានប្រសិទ្ធភាព នាងខ្ញុំនិងស្វាមីក៏ចាប់ផ្តើមបង្កើតក្រុមហ៊ុនឫទ្ធិពលនេះឡើងក្នុងឆ្នាំ២០១២ ដើម្បីផ្សព្វផ្សាយអំពីចំណេះដឹងហិរញ្ញវត្ថុ ក៏ដូចជាប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុផងដែរ។ រហូតមកដល់ឆ្នាំ២០២០ អាជីវកម្មរបស់ពួកយើងបានរងផលប៉ះពាល់មួយចំនួនពីវិបត្តិសកល គឺជម្ងឺកូវីដ-១៩ ប៉ុន្តែពួកយើងក៏នៅតែអាចឆ្លងកាត់បានមកដល់បច្ចុប្បន្ន។ កត្តាដែលលំបាកបំផុតនាពេលនោះគឺបញ្ហាខ្វះដើមទុន ជាពិសេសទុនបង្វិល ដើម្បីទ្រទ្រង់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។ នៅពេលនោះយើងបានប្រើប្រាស់ទ្រព្យរបស់យើងធ្វើជាទ្រព្យធានា ដើម្បីស្នើសុំកម្ចី ប៉ុន្តែពួកយើងនៅតែមិនអាចទទួលបានទុនគ្រប់គ្រាន់តាមតម្រូវការ។ ដំណោះស្រាយដ៏ល្អនាពេលនោះគឺមានការណែនាំពី ខេមា មីក្រូហិរញ្ញវត្ថុ ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដៃគូរបស់ CGCC ឲ្យពួកយើងស្នើសុំកម្ចីដែលមានការការធានាពី CGCC សម្រាប់អាជីវកម្មដោយមិនចាំបាច់មានទ្រព្យធានាគ្រប់គ្រាន់។

បន្ទាប់ពីទទួលបានទុនបង្វិលដែលមានការធានា យើងក៏អាចដោះស្រាយបញ្ហាសំខាន់ៗជាច្រើនដូចជាការចំណាយលើការធ្វើទីផ្សារ ការផ្សព្វផ្សាយនិងការចំណាយលើប្រត្តិបត្តិការអាជីវកម្មទាំងមូល។ យើងខ្ញុំបានពង្រីកអាជីវកម្មឲ្យធំជាងមុន មានបុគ្គលិកច្រើនជាងមុន អតិថិជនបានទទួលជ្រាប និងស្គាល់រួមជាមួយនឹងការប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំបានកើនឡើងជាលំដាប់។ ម្យ៉ាងទៀត យើងខ្ញុំក៏មានពេលវេលាច្រើនជាងមុន ដើម្បីគិតគូរទៅលើយុទ្ធសាស្រ្តថ្មីៗបន្ថែមទៀតដោយលែងបារម្ភពីបញ្ហាដើមទុនតទៅទៀត។

ដើម្បីឲ្យអាជីវកម្មមួយជោគជ័យទៅបានគឺអាស្រ័យលើកត្តាជាច្រើនក្នុងនោះដើមទុន ឬក៏ទុនបង្វិលគឺជាកត្តាសំខាន់បំផុតសម្រាប់អាជីវកម្មនីមួយៗ។ យើងខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាលដែលបានបង្កើត CGCC ឡើង និងបានជួយគាំទ្រដល់អាជីវកម្មរបស់យើងខ្ញុំ ក៏ដូចជាម្ចាស់អាជីវកម្មដ៏ទៃផ្សេងទៀត ឲ្យមានឱកាសរីកចម្រើនទៅបានយ៉ាងរលូន ក៏ដូចជាដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ចប្រទេសជាតិទាំងមូលផងដែរ៕

EN Seeing that the financial awareness of Cambodian people is still limited, and their use and management of finances are not very effective, my husband and I started this company RithyPul in 2012 to spread the knowledge and share financial advice. Until 2020, our business was affected by the COVID-19, however we can still get through it until today. The most difficult factor at that time was the lack of working capital to support day-to-day business operations. At that time, we used our property as collateral to apply for a loan, but we still could not get enough capital as needed. The best solution at that time was to have a CGCC's Participating Financial Institution, CAMMA Microfinance, advising us to apply for a CGCC guaranteed loan for our business, which would allow us to obtain a loan without collateral to use as working capital.

After obtaining guaranteed loans from Participating Financial Institution of CGGC, we are also able to address several key issues such as marketing, advertising, and overall business operation costs. We have expanded our business with more staff, and customers becoming more aware and acquainted with the use of our services has increased steadily. On the other hand, we also have more time to think about new strategies without having to worry about capital issues.

The success of a business depends on many factors, including having enough working capital, that is the most important factor for every business. We would like to thank the Government for establishing CGCC to support our business and other MSMEs on access to finance, as well as to improve financial inclusion in the country.